DOCUMENT RESUME

ED 356 674 FL 800 508

AUTHOR Pecoraro, Diane; Phommasouvanh, Bounlieng
TITLE Limited English Proficient (LEP) Parent Involvement Project. Overview [and] User's Guide. Cambodian.
INSTITUTION Minnesota State Dept. of Education, St. Paul. Office of Community and Adult Basic Education.
PUB DATE 91
NOTE 44p.; For English version, see ED 344 499; for the Hmong, Lao, Vietnamese, and Spanish versions, see FL 800 509-512.
PUB TYPE Reports - Descriptive (141) -- Guides - Non-Classroom Use (055)
LANGUAGE Cambodian

EDRS PRICE MF01/PC02 Plus Postage.
DESCRIPTORS *Acculturation; Adult Education; *Cambodians; Class Activities; Elementary Secondary Education; English (Second Language); *Immigrants; Instructional Materials; Lesson Plans; *Limited English Speaking; Parent Participation; *Parents as Teachers; *Parent School Relationship; Refugees; Values
IDENTIFIERS *Minnesota

ABSTRACT

The Limited English Proficient (LEP) Parent Involvement Project, a collaborative project between two state agencies, aims to help refugee and immigrant parents to be effective in their new American culture. Materials are provided that were developed for use in various adult education settings such as English-as-a-Second-Language (ESL) classes, community-based organizations, and parent groups for the purposes of helping LEP parents and caretakers see themselves as active participants in their children's learning. The following goals guided the development of the materials: (1) build on what people already know from their experience as parents in their own countries; (2) help parents restore their visions of themselves as the first and primary teachers of their children; (3) create opportunities for parents to build bridges between experiences in their new and native countries; and (4) encourage parents to define and keep values and traditions that are meaningful parts of their cultures. This document includes the following four instructional modules: Building the New and Old Cultures; Schools are Part of the Culture; Parents are Teachers; and Discipline (who teaches children, problems and punishment, communication, praising and rewarding, and types of resources). The accompanying user's guide for the teacher or community worker includes an introduction to the modules, suggestions for getting started and lesson planning, and suggested activities. Contains 7 references. (Adjunct ERIC Clearinghouse on Literacy Education) (KM)

****
* Reproductions supplied by EDRS are the best that can be made *
* from the original document. *
****

ED356674

Limited English Proficient (LEP) Parent Involvement Project

"PERMISSION TO REPRODUCE THIS MATERIAL HAS BEEN GRANTED BY

Peccorare, D.

TO THE EDUCATIONAL RESOURCES INFORMATION CENTER (ERIC)."

U.S. DEPARTMENT OF EDUCATION
Office of Educational Research and Improvement
EDUCATIONAL RESOURCES INFORMATION CENTER (ERIC)

☐ This document has been reproduced as received from the person or organization originating it.

☐ Minor changes have been made to improve reproduction quality.

• Points of view or opinions stated in this document do not necessarily represent official OERI position or policy.

FL 800508

Cambodian, 1991

BEST COPY AVAILABLE

កិច្ចការអំពី ការចូលរួមសកម្មភាព ពីសំណាក់មាតាបិតា ដែលមិនសូវស្គាត់ជំនាញខាង ភាសាអង់គ្លេស

ឯកសារ ១

ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
ផ្នែកការសិក្សាអប់រំ សហគម និង ជនពេញវ័យ
ផ្នែកសំរាប់ជនដែលមិនសូវស្គាត់ជំនាញខាងភាសាអង់គ្លេស

និទាឃរដូវ ឆ្នាំ ១៩៩១

សមាសភាពទី ១

ចំណាចពី ទប្បធម៌ថ្មី និង ទប្បធម៌ចាស់

ការបញ្ជាក្យគុណតវេទិតា

សមាសភាពទាំងអស់នេះ គឺកើតឡើងពីសហការរួម រវាង អ្នកស្រី Diane Pecoraro ផ្នែក ការសិក្សាអប់រំសំរាប់សហគម និងជនពេញវ័យ និងលោក Bounlieng Phommasouvanh ផ្នែកការសិក្សាអប់រំ សំរាប់ជនដែលមិនសូវស្គាត់ ជំនាញខាង ភាសាអង់គ្លេស។

អ្នកគ្រូ Judith Strohl ដែលជាគ្រូបង្រៀន ABE/ESL ពីមុន ហើយបច្ចុប្បន្ននេះ ជាគ្រូបង្រៀននៅអនុវិទ្យាល័យ Sanford នៅមីនីអាប៉ូលីស ប្រានជួយសរសេរ និង តាក់តែងសម្ភារៈសិក្សាទាំងនេះដែរ។

និក្ខេបបទ ឆ្នាំ ១៩៩១

ចំពោះ អ្នកប្រើឯកសារនេះ
នេះគឺជាចលនាទូទាំងប្រទេស ដែលបានបង្កើតឡើងដើម្បីពង្រឹង និង បង្កើនការចូលរួមសកម្មភាពពីសំណាក់មាតាបិតា ក្នុងការសិក្សាអប់រំបុត្ររបស់គាត់។ យើងមានជំនឿ និង ទ្រទ្រង់លើមតិ និង មាគានេះ ជាពិសេសចំពោះ មាតាបិតារបស់សិស្ស ដែលមិនសូវស្ទាត់ជំនាញលើភាសារអង់គ្លេស និងគ្រួសារជនភៀសខ្លួន ដែលមករស់នៅ ស្រុកអាមេរិក ក្នុងរយពេល ២០ឆ្នាំមុននេះ។ គ្រួសារទាំងនេះ បានប្រទះនឹងការពិបាកជាច្រើន អំពីបុត្ររបស់ខ្លួន ដែលកំពុងភ្ជាយខ្លួន ជាអាមេរិកាំង និងអំពីរបៀបសិក្សាអប់រំ នៅប្រទេសអាមេរិក ដែលមានសណ្ឋានភាពខុសគ្នា ពីរបៀបនៅប្រទេសដើមរបស់គាត់។

យើងបានបង្កើតសម្ភារៈសិក្សាសំរាប់ កម្មវិធីសិក្សាសំរាប់ជនពេញវ័យ ដូចជា កម្មវិធីសិក្សារអង់គ្លេស ជាភាសាទីពីរ កម្មវិធីសិក្សាតាមអង្គការនៅសហគម និងតាមក្រុមមាតាបិតា ក្នុងគោលបំណងដើម្បីជួយ មាតាបិតា និង អ្នកថែរក្សាក្មេង ដែលមិនសូវចេះភាសារអង់គ្លេស អោយក្លាយទៅជា អ្នកចូលរួមយ៉ាងសកម្ម ក្នុងការសិក្សា អប់រំក្មេង។
ពេលដែលយើងរៀបចំឯកសារនេះ យើងមានគោលបំណង ៖
១.ជួយកសាងបន្ថែម ពីលើអ្វីដែលមាតាបិតាបានធ្លាប់មានការពិសោធន៍ ក្នុងឋានៈ ជាមាតាបិតា ពីប្រទេសគាត់មក។
២.ជួយបំភ្លឺមាតាបិតា អោយដឹងថា ខ្លួនគាត់ជាគ្រូទី១ (ទស្សនៈ នេះតែងតែរលាយបាត់បង់ នៅពេលដែល គាត់បានភៀសខ្លួនមកនៅ ប្រទេសមួយទៀត)។
៣.ផ្តល់ឱកាសអោយ មាតាបិតាបញ្ចេញយោបល់មតិ អំពីអ្វីដែលខុសគ្នា និងដូចគ្នា រវាង វប្បធម៌ ថ្មី និង ចាស់ ហើយបង្កើតស្ពានភ្ជាប់វប្បធម៌ទាំងពីរនេះ។
៤.ដើម្បីជួយជំរុញទឹកចិត្តមាតាបិតា អោយចេះ អោយ និង រក្សាតម្លៃ និងទំនៀមទំលាប់ ដែលជាផ្នែកដ៏សំខាន់ នៃវប្បធម៌របស់គាត់។

វាជាភារកិច្ចមួយសំខាន់ណាស់ដែល យើងជួយពន្យល់មាតាបិតា ដែលទើបអញ្ជើញ មកដល់ថ្មី អោយបានយល់អំពី របៀបសិក្សាអប់រំនៅស្រុកអាមេរិក ហើយដើម្បីអោយ គាត់បាន យល់ដឹង ភារកិច្ចរបស់ខ្លួន លើការសិក្សាអប់រំក្មេង។ គ្រូ អ្នកបង្ហាត់ និងប្រធានសហគម អាចយកឯកសារនេះទៅប្រើ ជាមួយមាតាបិតា ដើម្បីជាមធ្យោបាយជួយ មាតាបិតាក្នុងការបង្កើត បច្ចេកទេស និង ទំនុកចិត្ត លើខ្លួនឯង ក្នុងការចាប់ផ្តើមជាជំហានទី១ ចំពោះការរួបរួមគ្នាជាធ្លុងមួយ ក្នុងការសិក្សាអប់រំក្មេង។

ដោយក្តីរាប់អាន

អ្នកស្រី Diane Pecoraro
ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
(៦១២) ២៨៦-៧៥០០

លោក Bounlieng Phommasouvanh
ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
(៦១២) ២៨៦-១០៦៨

ឬឮកថា

ជួយឪពុកម្តាយលោកអ្នកក្នុងការសិក្សារហូតដល់ជោគជ័យ

មាតាបិតាដែលទើបតែអញ្ជើញមកដល់ស្រុកអាមេរិកថ្មីៗ តែងតែមានការព្រួយបារម្ភ ចំពោះការសិក្សារបស់បុត្រខ្លួន និងមិនសូវដឹងអំពីភារកិច្ចរបស់ខ្លួន អំពីការសិក្សា របស់បុត្រខ្លួន។ មេរៀនបន្ទាប់ទៅ នឹងបកស្រាយ ឆ្លើយតបទៅនឹង បញ្ហាទាំងនោះ។ យើងបានរៀបចំមតិទស្សនៈ ដែលបញ្ជាក់ថា គ្រួសារ គឺជាកត្តាមួយ ដ៏មានឥទ្ធិពល ដែលទាក់ទងទៅនឹង ភាពជោគជ័យ ការទាក់ទាញចំណង់ចិត្ត និង ការអោយតម្លៃខ្លួនឯងរបស់សិស្ស។ លក្ខណៈទាំងអស់នេះ គឺមានឥទ្ធិពលដ៏ខ្លាំងក្លា ហើយដែលទាក់ទងនឹង ការជោគជ័យ របស់សិស្ស ក្នុងការសិក្សា។ លើសពីនេះទៅទៀត សមត្ថភាពរបស់ មាតាបិតា ក្នុងការណែនាំសិស្សនេះ មិនពឹងពាក់ទៅលើ ការស្ទាត់ជំនាញ លើភាសាអង់គ្លេសទេ។

សម្ភារៈទាំងនេះ គឺសំដៅទៅលើ ការជួយមាតាបិតាអោយស្គាល់ សមត្ថភាពរបស់ខ្លួន ក្នុងការចិញ្ចឹមថែរក្សាក្មេង ហើយដើម្បីសង្កត់បញ្ជាក់ថែមទៀតថា បច្ចេកទេស ដែលគាត់មាន មានសារសំខាន់ណាស់។ ប្រធានដែលយើងនឹងយកមកបង្ហាញ គឺជាជំហានមួយដ៏មហិមារ ក្នុងការចាប់ផ្តើមពិភាក្សា និងជួយគ្នាទៅវិញទៅមក រវាងមាតាបិតានៅក្នុងក្រុមជាមួយគ្នា។

សមាសភាពមានបីសណ្ឋាន ÷

១. ស្គាន់ចំលងរវាង វប្បធម៌ថ្មី និងវប្បធម៌ចាស់
   សិក្សារបៀបថ្មី ប៉ុន្តែ រក្សារបៀបចាស់
២. សាលារៀន គឺជាផ្នែកមួយនៃវប្បធម៌
៣. មាតាបិតា គឺជា គ្រូ

មេរៀននីមួយៗ មានអត្ថបទអានខ្លីៗ ដែលនឹងផ្តល់ ការបំភ្លឺទៅចំពោះសម្ភារៈ លំហាត់មួយឬពីរ ដើម្បីធ្វើការអនុវត្តន៍សាកល្បង និងពិភាក្សា ហើយនិង អត្ថបទរៀងរំពឹបញ្ហាខ្លះៗ ដើម្បីអោយសមាជិកក្នុងក្រុមរែកញែក ដោះស្រាយ និងបញ្ចេញប្រតិកម្ម។

លំហាត់ទាំងនោះ អាចធ្វើតាមក្រុម ដែលមាន ពីរនាក់ ក្រុមតូចៗ ឬតាម ក្រុមធំៗ ទៅតាមការសមគួរ។

យើងសង្ឃឹមថា គ្រួសារសិស្ស អាចបង្កើតបច្ចេកទេស និងបង្កើនទំនុកចិត្ត ក្នុងការចិញ្ចឹមថែរក្សាបុត្ររបស់ខ្លួន ក្នុងសង្គមវប្បធម៌ថ្មី ហើយធ្វើអោយគាត់ ចង់ចូលរួមជាសកម្ម ក្នុងការសិក្សារបរំ របស់បុត្រខ្លួន ទាំងនៅសាលា និងនៅផ្ទះ។

ទស្សនៈទូទៅ_____

តាមការស្រាវជ្រាវអំពីភារកិច្ចរបស់មាតាបិតា នៅសាលារៀនបានបង្ហាញថា÷

*មាតាបិតាគឺជាគ្រូទី១ ហើយជាគ្រូ ដែលមានឥទ្ធិពលជាងគេ។

*សាលារៀនចង់ និងត្រូវការជំនួយពីសំណាក់មាតាបិតា។

*ការនិយាយភាសាអង់គ្លេសរត់មាត់ មិនមែនជាការត្រូវការចាំបាច់ ក្នុងការបង្កើតបរិយាការល្អ សំរាប់ការសិក្សាទេ។

*ការសិក្សារបស់សិស្ស អាចបានលូតលាស់ល្អនៅពេលមាតាបិតា÷

១.ជួយតម្កើង តម្លៃខ្លួនរបស់សិស្ស នេះរាប់បញ្ចូលទាំង ការអោយតម្លៃ វប្បធម៌របស់គេផង។

២.បង្ហាញថា មាតាបិតាអោយតម្លៃទៅលើការសិក្សា ដោយ ទៅធ្វើទស្សនកិច្ច នៅសាលា សាកសួរអំពីសាលារៀន និងតាំងបង្ហាញកិច្ចការដែលសិស្សបានធ្វើជាដើម។

៣.និយាយ អាន និង ពន្យល់អំពី បញ្ហា ឬ របស់ផ្សេងៗ ទៅសិស្ស។

៤.ពិនិត្យត្រួតមើល នូវចំនួនពេលម៉ោង និង ប្រភេទនៃកម្មវិធីទូរទស្សន៍ ដែលក្មេងមើល។

៥.ធ្វើកាលវិភាគ សំរាប់ពេលម៉ោង ធ្វើកិច្ចការសាលារៀន បរិភោគអាហារ និង ពេលចូលដំណេក។

៦.រៀបចំកន្លែងពិសេស សំរាប់សិស្សសិក្សានៅផ្ទះ។

៧.កំរិតចំនួនម៉ោង ដែលសិស្សអាចធ្វើការងារក្រោយម៉ោងសាលារៀន។

សមាសភាពទី ១ ÷
ស្ពានឆម្លង វប្បធម៌ថ្មី និង វប្បធម៌ចាស់

អ្វីទៅជាវប្បធម៌?

យើងគឺដូចជាសត្វត្រី វប្បធម៌គឺជាទឹកដែលយើងហែល ហើយដែលនៅជុំវិញ យើងទាំងអស់គ្នា។ ពេលដែលយើង លោតចេញពីទឹក យើងនឹងដឹងថា យើងត្រូវការទឹកប៉ុណ្ណាដែរ។

ពេលដែលយើងឃ្លាតចេញពី វប្បធម៌របស់យើង ឬ ប៉ាត់បង់ វប្បធម៌របស់យើង ទើបយើងដឹងថា វប្បធម៌របស់យើង មានសារសំខាន់។

សូមអ្នកធ្វើការពិចារណា សំណួរខាងក្រោមនេះ ÷

*អ្វីខ្លះ និង ពេលណាដែលអ្នកចូលចិត្តបរិភោគ ?

*តើអ្នកកាន់សាសនាអ្វីដែរ?

*បើសិនជាមាន ពិធីបុណ្យជប់លៀងចាប់ផ្តើមនៅម៉ោង ៨ តើអ្នកអញ្ជើញទៅដល់នៅម៉ោងប៉ុន្មាន?

*តើពេលណា ដែលបុរស និង ស្ត្រី ត្រូវរៀបការ?

*តើស្លឹដែលមានសារសំខាន់ ចំពោះលោកអ្នក?

ប្រជាជនដែលមកពីវប្បធម៌ផ្សេងៗ នឹងអោយចម្លើយខុសៗ គ្នាតបទៅសំណួរខាងលើនោះ។

ប្រជាជនដែលមានវប្បធម៌ផ្សេងគ្នាៗ មិនមានសំលៀកបំពាក់ដូចគ្នាទេ ហើយបរិភោគម្ហូបខុសគ្នា។ លើសពីនេះទៅទៀត គំនិតយោបល់ ក៏ខុសគ្នាដែរ។

<u>សកម្មភាព៖ តារាងវប្បធម៌</u>

ក. ត្រិះរិះ អំពីវប្បធម៌អ្នក និងវប្បធម៌អាមេរិកាំង ហើយសរសេរនូវអ្វី
ដែលខុសគ្នា ដាក់ក្នុងតារាងខាងក្រោម។
ជជែកពិភាក្សាចម្លើយរបស់អ្នកជាមួយក្រុមរបស់អ្នក។

តារាងវប្បធម៌

	វប្បធម៌ខ្ញុំ	**វប្បធម៌អាមេរិកាំង**
ម្ហូបអាហារ		
ការពិសារបាយ		
សំលៀកបំពាក់		
ការបើកបរ		
¯រៀបដាក់ឯកសារ នៅកន្លែងធ្វើការ		
គ្រួសារ		
មាតាបិតា		
មិត្តភក្តិ		
របស់ដែលសំខាន់ជាង គេនៅក្នុងលោកនេះ		

តារាងវប្បធម៌ (ក)

	វប្បធម៌ខ្ញុំ	វប្បធម៌អាមេរិកាំង
ចាស់ទុំ		
សាលារៀន		
គ្រូបង្រៀន		
សាសនា		
ប្រាក់កាស់		
ការព្យាបាលរោគ		
ការរៀបការ		
ការដើរលេងជាមួយគ្នារវាងបុរសនិងស្ត្រី		
កូនក្មេង		

ខ.<u>សំណួរសំរាប់ការពិភាក្សាបន្ថែម</u>

១. ត្រឹះរឹះ អំពីអ្វីដែលដូចគ្នារវាងវប្បធម៌អ្នក និង វប្បធម៌ថ្មី។

២.អ្វីដែលជាវប្បធម៌របស់អ្នក ហើយដែលអ្នកចង់រក្សា ទុកអោយមាន
នៅសហរដ្ឋអាមេរិក?

៣.អ្វីខ្លះដែលជាវប្បធម៌របស់អ្នក ហើយដែលអ្នកមានការពិបាក ក្នុងការរក្សា
វប្បធម៌ទាំងនោះនៅសហរដ្ឋអាមេរិក?

បច្ចឹតមោឧនភាព ទៅចំពោះវប្បធម៌អ្នក

បុត្រអ្នកនឹងត្រូវបានទទួលបំណែកក្នុងវប្បធម៌ពីរ ឬលើសពី ពីរវប្បធម៌ទៅទៀត។ វានឹងត្រូវទទួល វប្បធម៌របស់គ្រួសារវា និង វប្បធម៌របស់អាមេរិក។ នេះជាសំណាងមួយ ប៉ុន្តែវា ក៏ត្រូវពុះពារខុបស័ក្តដ៏ធំមួយដែរ។
ពេលខ្លះ មិនមែនជាការងាយស្រួយទេ នៅពេលដែលយើងត្រូវរស់នៅ ក្នុងវប្បធម៌ពីរ។
ក្មេងច្រើនតែភ្លេចវប្បធម៌កំណើតរបស់ខ្លួនខ្លះ នៅពេលដែល វាត្រូវរស់នៅក្នុងវប្បធម៌ថ្មី។ ពេលខ្លះទៀត ក្មេងមានការពិបាកក្នុងការជ្រើសរើស រវាង គំនិត យោបល់ ពីគ្រួសារវា និង គំនិត យោបល់ ដែល ឮនិងឃើញ ពី ទូរទស្សន៍ ខ្សែភាពយន្ត និងពី សាលារៀន។
គ្រួសារ និង សហគម អាចធ្វើកិច្ចការច្រើន ដើម្បីរក្សាវប្បធម៌របស់ខ្លួន នៅប្រទេសអាមេរិក។
យើងអាចបង្រៀនក្មេងៗ អំពីវប្បធម៌កំណើត ដើម្បីកុំអោយក្មេងភ្លេចវប្បធម៌កំណើតរបស់ខ្លួន។
យើងអាចបង្រៀនក្មេង អោយចេះ យល់ ស្រឡាញ់ចូលចិត្តវប្បធម៌ទាំងពីរ។

លំហាត់ ÷ សរសេរ និង ពិភាក្សា

ក.តើទាហានសារសំខាន់អ្វី ដែលយើងត្រូវរក្សាទប្បធម៌កំណើតរបស់យើង នៅសហរដ្ឋអាមេរិក?

១.

២.

៣.

ខ.តើមានអ្វីខ្លះ ដែលអ្នកអនុវត្ត ដើម្បីរក្សា និង ចងចាំ ទប្បធម៌របស់អ្នក?

១.

២.

៣.

<u>កិច្ចការយកទៅធ្វើនៅផ្ទះ</u>

ចូរអានលំហាត់ខាងក្រោម ហើយជ្រើសរើសលំហាត់មួយ មកអនុវត្ត ជាមួយគ្រួសារអ្នក។ រាយការអំពីសកម្មភាពនោះ ទៅក្រុមដែលអ្នក ត្រូវជួប ប្រជុំលើកក្រោយ។

១.ចាប់ផ្តើមដោយប្រើ សៀវភៅព្រៀង ហើយគូររូបដែលស្តីអំពីវប្បធម៌អ្នក

២.លេងល្បែងកំសាន្តជាមួយបុត្រអ្នក។ លេងល្បែងដែល អ្នកធ្លាប់លេង នៅពេលដែលអ្នកនៅក្មេង។

៣.និទានរឿងប្រាប់បុត្រអ្នក រឿងដែលមាតាបិតាអ្នកធ្លាប់និយាយប្រាប់អ្នក កាលដែលអ្នកនៅក្មេង។

៤.បង្រៀនបុត្រអ្នកអំពី ចម្រៀង និង របាំ ដែលអ្នកចេះ កាលដែលអ្នកនៅក្មេង។

៥.ធ្វើអ្វីដែលពិសេស ដែលអ្នករៀនពីគ្រួសារអ្នក ជាមួយបុត្រអ្នក។

៦.អោយរបស់ដែលជាកេរ្តិ៍ដំណែល មកពីវប្បធម៌អ្នក ទៅបុត្រអ្នកអោយយកទៅ សាលារៀន ហើយអោយក្មេងពន្យល់អំពីរបស់នោះដល់គ្រូ។ ឧទាហរណ៍ ÷ រូបថត គ្រឿងដូរតន្ត្រី ម្ហូបអាហារ ឬ សំលៀកបំពាក់ពិសេស។

៧.សំណើររបស់អ្នក÷

<u>លំហាត់ ក្រុមរួមគ្នា៖ មាតាបិតា និង បុត្រ</u>

ពេលដែលមានកើតព្រឹត្តិការណ៍សំខាន់ៗ ដែលកើតមានឡើង នៅក្នុង
ជីវិតរស់នៅរបស់យើង



<u>របៀបអនុវត្ត</u>

១.អនុវត្តជាមួយបុត្រលោកអ្នក
២.ជ្រើសរើសយកអាយុខុសៗគ្នា
៣.បំពេញ ហេតុការណ៍សំខាន់ៗ ដែលកើតឡើងតាមអាយុចុះខាងលើ
៤.ប្រៀបធៀបអ្វីដែលដូចគ្នា និងអ្វីដែលខុសគ្នា
៥.ពន្យល់មូលហេតុ អំពីស្ទ្រីដែលខុសគ្នា រវាងវប្បធម៌ចាស់និងថ្មី

<u>ខ្ចោះ</u> *ក្មេងសម័យឥឡូវចូលរៀន អាយុ ៥ឆ្នាំ។*
មាតាបិតាចូលរៀនអាយុ ៦ឆ្នាំ។

<u>សកម្មភាព ផ្នែកការអាន÷ រឿងដែលមានបញ្ហាត្រូវដោះស្រាយ</u>

លោកហាយ និង បុត្រៗរបស់គាត់

លោកហាយមានអាយុ ៥៥ឆ្នាំ។ គាត់បានអញ្ជើញមកពីប្រទេស វៀតណាមជាមួយ ភរិយាគាត់ និងបុត្រ៤នាក់។ គាត់មិនសូវចេះភាសាអង់គ្លេស។
បុត្ររបស់គាត់ចេះនិយាយភាសាអង់គ្លេសស្ទាត់ ហើយថែមទាំង មានមិត្តភ័ក្ត្រ ដែលជាជនជាតិអាមេរិកច្រើន។
បុត្របងបង្អស់ចេះអានអក្សរវៀតណាម ប៉ុន្តែ មិនចង់និយាយ ភាសាវៀតណាម។ បុត្របួនចេះ យល់ ភាសាវៀតណាម បន្តិចបន្តួច។ បញ្ហាទាំងអស់នេះ បានធ្វើអោយ លោកហាយ មិនសប្បាយចិត្ត។
លោកហាយ មិនសប្បាយចិត្តនឹងបញ្ហាមួយទៀត គឺថា បុត្ររបស់គាត់ស្លៀកសំលៀកបំពាក់ និង កាត់សក់ តាមរបៀបចម្លែក។ ទាំងនេះធ្វើអោយ លោកហាយមានការអាម៉ាសមុខ។

<u>សំណួរ</u>

១.ហេតុអ្វីបានជាលោកហាយមិនសប្បាយចិត្ត?

២.តើលោកហាយអាយពន្យល់បញ្ហារបស់គាត់ជាភាសាអង់គ្លេសរបៀបណា?

៣. ក.តើគាត់អាចសួរសំណួរអ្វីទៅបុត្ររបស់គាត់?

ខ.តើអ្នកគិតថា បុត្ររបស់គាត់នឹងឆ្លើយទៅគាត់របៀបណា?

៤.តើគាត់អាចទៅនិយាយជ្រាប់អ្នកណា នៅក្នុងសហគមវៀតណាម?

៥.តើគាត់អាចទៅនិយាយជ្រាប់អ្នកណា នៅសាលារៀន?

៦.តើអ្នកមានដំបូន្មានអ្វី សំរាប់លោកហាយ?

កិច្ចការអំពី ការចូលរួមសកម្មភាព ពីសំណាក់មាតាបិតា ដែលមិនសូវស្ទាត់ជំនាញខាង ភាសាអង់គ្លេស

ភាគ ២

ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
ផ្នែកការសិក្សាអប់រំ សហគម និង ជនពេញវ័យ
ផ្នែកសំរាប់ជនដែលមិនសូវស្ទាត់ជំនាញខាងភាសាអង់គ្លេស

និទាឃរដូវ ឆ្នាំ ១៩៩១

សមាសភាពទី ២

សាលារៀន គឺជា ផ្នែកមួយ នៃ ទប្បធម៌

ការបញ្ជាក់ទទួលភតវេទិតា

សមាសភាពទាំងអស់នេះ គឺកើតឡើងពីសហការរួម រវាង អ្នកស្រី Diane Pecoraro ផ្នែក ការសិក្សាអប់រំសំរាប់សហគម និងជនពេញវ័យ និងលោក Bounlieng Phommasouvanh ផ្នែកការសិក្សាអប់រំ សំរាប់ជនដែលមិនសូវស្ទាត ជំនាញខាង ភាសាអង់គ្លេស។

អ្នកគ្រូ Judith Strohl ដែលជាគ្រូបង្រៀន ABE/ESL ពីមុន ហើយបច្ចុប្បន្ននេះ ជាគ្រូបង្រៀននៅអនុទិទ្យាល័យ Sanford នៅមីនីអាប៉ូលីស ឬានជួយសរសេរ និង តាក់តែងសម្ភារៈសិក្សាទាំងនេះដែរ។

និក្ខេបជូន ឆ្នាំ ១៩៩១

ចំពោះ អ្នកប្រើឯកសារនេះ
នេះគឺជាចលនាទូទាំងប្រទេស ដែលបានបង្កើតឡើងដើម្បីពង្រឹង និង បង្កើនការចូលរួមសកម្មភាពពីសំណាក់មាតាបិតា ក្នុងការសិក្សាអប់រំបុត្ររបស់គាត់។ យើងមានជំនឿ និង ទ្រទ្រង់លើមតិ និង មាគានេះ ជាពិសេសចំពោះ មាតាបិតារបស់សិស្ស ដែលមិនសូវស្ទាត់ជំនាញលើភាសាអង់គ្លេស និងគ្រួសារជនភៀសខ្លួន ដែលមករស់នៅ ស្រុកអាមេរិក ក្នុងរយពេល ២០ឆ្នាំមុននេះ។ គ្រួសារទាំងនេះ បានប្រទះនឹងការពិបាកជាច្រើន អំពីបុត្ររបស់ខ្លួន ដែលកំពុងក្លាយខ្លួន ជាអាមេរិកាំង និងអំពីរបៀបសិក្សាអប់រំ នៅប្រទេសអាមេរិក ដែលមានសណ្ឋានភាពខុសគ្នា ពីរបៀបនៅប្រទេសដើមរបស់គាត់។

យើងបានបង្កើតសម្ភារៈសិក្សាសំរាប់ កម្មវិធីសិក្សាសំរាប់ជនពេញវ័យ ដូចជា កម្មវិធីសិក្សាអង់គ្លេស ជាភាសាទីពីរ កម្មវិធីសិក្សាតាមអង្គការនៅសហគម និងតាមក្រុមមាតាបិតា ក្នុងគោលបំណងដើម្បីជួយ មាតាបិតា និង អ្នកថែរក្សាក្មេង ដែលមិនសូវចេះភាសាអង់គ្លេស អោយក្លាយទៅជា អ្នកចូលរួមយ៉ាងសកម្ម ក្នុងការសិក្សា អប់រំក្មេង។
ពេលដែលយើងរៀបចំឯកសារនេះ យើងមានគោលបំណង ៖
១.ជួយកសាងបន្ថែម ពីលើអ្វីដែលមាតាបិតាបានធ្លាប់មានការពិសោធន៍ ក្នុងឋានៈ ជាមាតាបិតា ពីប្រទេសគាត់មក។
២.ជួយបំភ្លឺមាតាបិតា អោយដឹងថា ខ្លួនគាត់ជាគ្រូទី១ (ទស្សនៈ នេះតែងតែរលាយបាត់បង់ នៅពេលដែល គាត់បានភៀសខ្លួនមកនៅ ប្រទេសមួយទៀត)។
៣.ផ្តល់ឱកាសអោយ មាតាបិតាបញ្ចេញយោបល់មតិ អំពីអ្វីដែលខុសគ្នា និងដូចគ្នា រវាង វប្បធម៌ ថ្មី និង ចាស់ ហើយបង្កើតស្ពានភ្ជាប់វប្បធម៌ទាំងពីរនេះ។
៤.ដើម្បីជួយជំរុញទឹកចិត្តមាតាបិតា អោយចេះ អោយ និង រក្សាតម្លៃ និងទំនៀមទំលាប់ ដែលជាផ្នែកដ៏សំខាន់ នៃវប្បធម៌របស់គាត់។

វាជាភារកិច្ចមួយសំខាន់ណាស់ដែល យើងជួយពន្យល់មាតាបិតា ដែលទើបអញ្ជើញ មកដល់ថ្មី អោយបានយល់អំពី របៀបសិក្សាអប់រំនៅស្រុកអាមេរិក ហើយដើម្បីអោយ គាត់បាន យល់ដឹង ភារកិច្ចរបស់ខ្លួន លើការសិក្សាអប់រំក្មេង។ គ្រូ អ្នកបង្ហាត់ និងប្រធានសហគម អាចយកឯកសារនេះទៅប្រើ ជាមួយមាតាបិតា ដើម្បីជាមធ្យោបាយជួយ មាតាបិតាក្នុងការបង្កើត បច្ចេកទេស និង ទំនុកចិត្ត លើខ្លួនឯង ក្នុងការចោះដំហានទី១ ចំពោះការរួបរួមគ្នាជាផ្លូងមួយ ក្នុងការសិក្សាអប់រំក្មេង។

ដោយក្តីរាប់អាន

អ្នកស្រី Diane Pecoraro
ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
(៦១២) ២៩៦-៧៥០០

លោក Bounlieng Phommasouvanh
ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
(៦១២) ២៩៦-១០៦៤

ឬឮកថា

ជួយបុត្រលោកអ្នកក្នុងការសិក្សាអោយបានជោគជ័យ

មាតាបិតាដែលទើបតែអញ្ជើញមកដល់ស្រុកអាមេរិកថ្មីៗ តែងតែមានការព្រួយបារម្ភ ចំពោះការសិក្សារបស់បុត្រខ្លួន និងមិនសូវដឹងអំពីការកិច្ចរបស់ខ្លួន អំពីការសិក្សា របស់បុត្រខ្លួន។ មេរៀនបន្ទាប់ទៅ នឹងបកស្រាយ ឆ្លើយតបទៅនឹង បញ្ហាទាំងនោះ។ យើងបានរៀបចំមតិទស្សនៈ ដែលបញ្ជាក់ថា គ្រួសារ គឺជាកត្តាមួយ ដ៏មានឥទ្ធិពល ដែលទាក់ទងទៅនឹង ភាវៈមានយោទ្ធ វិន័យ ការទាក់ទាញចំណង់ចិត្ត និង ការអោយតម្លៃខ្លួនឯងរបស់សិស្ស។ លក្ខណៈទាំងអស់នេះ គឺមានឥទ្ធិពលដ៏ខ្លាំងក្លា ហើយដែលទាក់ទងនឹង ការជោគជ័យ របស់សិស្ស ក្នុងការសិក្សា។ លើសពីនេះទៅទៀត សមត្ថភាពរបស់ មាតាបិតា ក្នុងការណែនាំសិស្សនេះ មិនពឹងពាក់ទៅលើ ការស្ទាត់ជំនាញ លើភាសាអង់គ្លេសទេ។

សម្ភារៈទាំងនេះ គឺសំដៅទៅលើ ការជួយមាតាបិតាអោយស្គាល់ សមត្ថភាពរបស់ខ្លួន ក្នុងការចិញ្ចឹមថែរក្សាក្មេង ហើយដើម្បីសង្កត់បញ្ជាក់ថែមទៀតថា បច្ចេកទេស ដែលគាត់មាន មានសារសំខាន់ណាស់។ ប្រធានដែលយើងនឹងយកមកបង្ហាញ គឺជាជំហានមួយដ៏មហិមារ ក្នុងការចាប់ផ្តើមពិភាក្សា និងជួយគ្នាទៅវិញទៅមក រវាងមាតាបិតានៅក្នុងក្រុមជាមួយគ្នា។

សមាសភាពមានចីសណ្ឋាន ÷

១. ស្គាននៅលងរវាង វប្បធម៌ថ្មី និងវប្បធម៌ចាស់
   សិក្សារបៀបថ្មី ប៉ុន្តែ រក្សារបៀបចាស់
២. សាលារៀន គឺជាផ្នែកមួយនៃវប្បធម៌
៣. មាតាបិតា គឺជា គ្រូ

មេរៀននីមួយៗ មានអត្ថបទអានខ្លីៗ ដែលនឹងផ្តល់ ការបំភ្លឺទៅចំពោះសម្ភារៈ លំហាត់មួយឬពីរ ដើម្បីធ្វើការអនុវត្តន៍សាកល្បង និងពិភាក្សា ហើយនិង អត្ថបទរឿងអំពីបញ្ហាខ្លះៗ ដើម្បីអោយសមាជិកក្នុងក្រុមរែកព្យែក ដោះស្រាយ និងបញ្ចោញប្រតិកម្ម។

លំហាត់ទាំងនោះ អាចធ្វើតាមក្រុម ដែលមាន ពីរនាក់ ក្រុមតូចៗ ឬតាម ក្រុមធំៗ ទៅតាមការសមគួរ។

យើងសង្ឃឹមថា គ្រួសារសិស្ស អាចបង្កើតបច្ចេកទេស និងបង្កើនទំនុកចិត្ត ក្នុងការចិញ្ចឹមថែរក្សាបុត្ររបស់ខ្លួន ក្នុងសង្គមវប្បធម៌ថ្មី ហើយធ្វើអោយគាត់ ចង់ចូលរួមជាសកម្ម ក្នុងការសិក្សាអប់រំ របស់បុត្រខ្លួន ទាំងនៅសាលា និងនៅផ្ទះ។

ទស្សនៈទូទៅ

តាមការស្រាវជ្រាវអំពីភារកិច្ចរបស់មាតាបិតា នៅសាលារៀនបានបង្ហាញថា÷

*មាតាបិតាគឺជាគ្រូទី១ ហើយជាគ្រូ ដែលមានឥទ្ធិពលជាងគេ។

*សាលារៀនចង់ និងត្រូវការជំនួយពីសំណាក់មាតាបិតា។

*ការនិយាយភាសាអង់គ្លេសរត់មាត់ មិនមែនជាការត្រូវការចាំបាច់ ក្នុងការបង្កើតបរិយាការណ៍ សំរាប់ការសិក្សាទេ។

*ការសិក្សារបស់សិស្ស អាចបានលូតលាស់ល្អនៅពេលមាតាបិតា÷

១.ជួយតម្កើង តម្លៃខ្លួនរបស់សិស្ស នេះរាប់បញ្ចូលទាំង ការអោយតម្លៃ វប្បធម៌របស់គេផង។

២.បង្ហាញថា មាតាបិតាអោយតម្លៃទៅលើការសិក្សា ដោយ ទៅធ្វើទស្សនកិច្ច នៅសាលា សាកសួរអំពីសាលារៀន និងតាំងបង្ហាញកិច្ចការដែលសិស្សបានធ្វើជាដើម។

៣.និយាយ អាន និង ពន្យល់អំពី បញ្ហា ឬ របស់ផ្សេងៗ ទៅសិស្ស។

៤.ពិនិត្យត្រួតមើល នូវចំនួនពេលម៉ោង និង ប្រភេទនៃកម្មវិធីទូរទស្សន៍ ដែលក្មេងមើល។

៥.ធ្វើកាលវិភាគ សំរាប់ពេលម៉ោង ធ្វើកិច្ចការសាលារៀន បរិភោគអាហារ និង ពេលចូលដំណេក។

៦.រៀបចំកន្លែងពិសេស សំរាប់សិស្សសិក្សានៅផ្ទះ។

៧.កំរិតចំនួនម៉ោង ដែលសិស្សអាចធ្វើការងារក្រោយម៉ោងសាលារៀន។

សមាសភាពទី ២ ÷ សាលារៀន គឺជា ផ្នែកមួយនៃវប្បធម៌

សាលារៀននីមួយៗ ពុំមានលក្ខណៈដូចគ្នាទេ គឺអាស្រ័យទៅតាម កន្លែងផ្សេងៗគ្នា។ សាលារៀន ខុសគ្នាទៅតាម ប្រទេស និងតាមវប្បធម៌។ គ្រូក៏មានការទទួលខុសត្រូវផ្សេងៗគ្នាដែរ។ ចំណែកសិស្ស ក៏ មានកិរិយាមារយាទ និង សិក្សាតាមរបៀប ខុសគ្នាដែរ។

<u>លេខ្យិបអនុទត្ត</u>

១.ត្រិះរិះ អំពីសាលារៀននៅប្រទេសរបស់អ្នក

២.សរសេរថា ពិត ឬ មិនពិត អំពីឃ្លាដែលចារនៅខាងក្រោមនេះ

៣.ពិភាក្សាចម្លើយរបស់អ្នក ជាមួយនឹងក្រុមរបស់អ្នក

ក.នៅប្រទេសរបស់ខ្ញុំ

----១.ក្មេងទាំងអស់ទៅសាលារៀន

----២.ក្មេងទៅសាលារៀនរហូតដល់អាយុ ១៦ឆ្នាំ

----៣.សិស្ស គោរព គ្រូ

----៤.មាតាបិតាជួយសិស្ស ក្នុងការធ្វើកិច្ចការសាលា នៅផ្ទះ

----៥.សិស្ស ត្រូវទន្ទេញចាំមេរៀន

----៦.មានកិច្ចការសាលាច្រើន យកមកធ្វើនៅផ្ទះ

----៧.គ្រូ រាប់អានជិតស្និត ជាមួយសិស្ស

----៨.ជនគ្រប់រូបនៅប្រទេសខ្ញុំ រៀនសរសេរ និងរៀនអាន

----៩.គ្រូអាចវាយសិស្ស បើសិនជាសិស្សប្រព្រឹត្ត មិនត្រឹមត្រូវ តាមច្បាប់ជាធរមាន

----១០.សិស្សទៅរៀននៅសាលាប្រាំថ្ងៃ ក្នុងមួយអាទិត្យ

ខ. សរសេរឃ្លាដែលពិត អំពីសាលារៀននៅប្រទេសអ្នក។

សាលារៀន គឺជា ផ្នែកមួយនៃវប្បធម៌

របៀបអនុវត្ត

ចូរធ្វើការប្រៀបធៀបសាលារៀននៅប្រទេសអ្នក ទៅនឹងសាលារៀននៅប្រទេសអាមេរិក។ រកមើលអ្វីដែលខុសគ្នា ហើយសរសេរនៅតារាងខាងក្រោម។ ពិភាក្សាចម្លើយរបស់អ្នក ជាមួយនឹងក្រុមរបស់អ្នក។

តារាងសាលារៀន

	នៅប្រទេសខ្ញុំ	នៅស្រុកអាមេរិក
អ្នកណាទៅសាលារៀន		
ការកិច្ចសាលារៀន		
សិស្សទៅរៀនប៉ុន្មានឆ្នាំ		
គ្រូបង្រៀនសិស្សតាមរបៀបណា?ឧទាហរណ៍÷ ចម្លងមេរៀនរៀនតាមក្រុម សួរសំណួរ។ល។		
សិស្សត្រូវប្រព្រឹត្តរបៀបណានៅក្នុងថ្នាក់រៀន?		
គ្រូបង្រៀន មុខវិជ្ជាអ្វីខ្លះ?		

	នៅប្រទេសខ្មែរ	នៅស្រុកអាមេរិក
តើគេប្រើសម្ភារៈ អ្វីខ្លះដើម្បីជាជំនួយក្នុងការសិក្សា?(សៀវភៅ ខ្សែភាពយន្ត ការធ្វើដំណើរទៅក្រៅកន្លែងពិសោធន៍ ។ល។)		
ហេតុអ្វី បានជាមនុស្សទៅរៀន?		
តើសិស្ស មានកិរិយាមារយាទ របៀបណា ទៅចំពោះគ្រូ?		
តើមានកិច្ចការសាលា យកមកធ្វើនៅផ្ទះច្រើនប៉ុន្មាន?		
តើមានក្លឹប ឬ កីឡាលេង ក្រោយម៉ោងសាលារៀនទេ?		
តើមាតាបិតាជួយសិស្ស នៅសាលារៀនតាមរបៀបណា?		

<u>សំណួរសំរាប់ពិភាក្សាបន្ថែម</u>

ក. ត្រិះរិះ មើលអ្វីដែលដូចគ្នា សំរាប់សាលារៀននៅប្រទេសអ្នក និង នៅប្រទេសថ្មីនេះ។

ខ. តើអ្វីដែលខុសគ្នា រវាងសាលារៀន នៅប្រទេសអ្នក និង ប្រទេសថ្មីនេះ ហើយដែលមានសារៈសំខាន់ជាងគេ?

ការអាន ៖ រឿងដែលមានបញ្ហាត្រូវដោះស្រាយ

ភ្លើបនិងសកម្មភាពក្រោយម៉ោងសិក្សា

អ្នកស្រី ស៊ូសាណា មានបញ្ហាមួយ។ គាត់ធ្វើការរាល់ថ្ងៃ ដើម្បីចិញ្ចឹមកូនគាត់ទាំងបីនាក់។ កូនស្រីគាត់ ម៉ារីយ៉ា អាយុ ១៣ឆ្នាំ កូនប្រុសគាត់ រ៉ូប៊ែតូ អាយុ ១៨ ឆ្នាំ និង ហ្គូន អាយុ ៥ឆ្នាំ។ ម៉ារីយ៉ា តែងតែជួយមើលប្អូនប្រុស ក្រោយពីពេលចេញពី សាលារៀន ដើម្បីអោយម្តាយនាងទៅធ្វើការ។
ឥឡូវនេះ ម៉ារីយ៉ាចង់ទៅហាត់លេងភ្លេង នៅក្រុមភ្លេងសាលារៀន។ នាងចូលចិត្តដូរតន្ត្រី ហើយនាងចង់រៀនផ្នែកខ្លួយ។ ប៉ុន្តែក្រុមតន្ត្រីនេះត្រូវនៅហាត់លេងភ្លេង ក្រោយម៉ោង សាលារៀនពីរដងក្នុងមួយអាទិត្យ។ នាងនិយាយថា÷ នាងនឹងអាចក្លាយជា អ្នកលេងភ្លេងមួយ ដ៏ចំណាន បើសិនជានាង នៅហាត់លេងភ្លេង ក្រោយម៉ោងសិក្សា សាលារៀន។ ហើយបើនាងទៅរៀននៅ មហាវិទ្យាល័យ នាងក៏ត្រូវនៅ ធ្វើកិច្ចការ ក្រោយម៉ោងសាលារៀនដែរ។ ម្តាយនាង មានប្រសាសន៍ថា÷ នាងត្រូវតែនៅផ្ទះ មើលប្អូនប្រុស។ ភ្លេង ដូរតន្ត្រីមិនមែនជាការសំខាន់ទេ។

១.តើអ្នកស្រី ស៊ូសាណា អាចពន្យល់ពី បញ្ហារបស់គាត់យ៉ាងណា?

២.តើសំណួរអ្វីដែលអ្នកស្រី អាចលើកយកមកសួរ ម៉ារីយ៉ា និង រ៉ូបែរតូ បាន?

៣.តើអ្នកស្រីអាចពិភាក្សាជាមួយអ្នកណា ដែលនៅក្នុងគ្រួសារ អំពីបញ្ហារបស់គាត់?

៤.តើអ្នកស្រីអាចពិភាក្សាជាមួយអ្នកណា ដែលនៅក្នុងសហគម អំពីបញ្ហារបស់គាត់?

៥.តើអ្នកស្រីអាចពិភាក្សាជាមួយអ្នកណា ដែលនៅសាលារៀន?

៦.តើអ្នកមានយោបល់អ្វីសំរាប់ ម៉ារីយ៉ា និង រ៉ូបែរតូ ទេ?

<u>ការអាន ÷ រឿងដែលមានបញ្ហាដោះស្រាយ</u>

បុត្ររបស់ខ្ញុំមិនធ្វើកិច្ចការសាលាដែលត្រូវយកមកធ្វើនៅផ្ទះ

លោកប៉ាងមានការព្រួយបារម្ភ អំពីបុត្ររបស់គាត់ ឈ្មោះតុងដែលមានអាយុ ១៥ឆ្នាំ ហើយទៅរៀននៅវិទ្យាល័យ។ តុងជាក្មេងល្អ តែមិនដែលមានកិច្ចការសាលាយកមកធ្វើ នៅផ្ទះសោះ។ លោកប៉ាងមិនដឹងថា តុងមានកិច្ចការសាលាដែលត្រូវយកមកធ្វើនៅផ្ទះទេ ពីព្រោះថាគាត់មិនដែលឃើញ តុងសិក្សានៅផ្ទះឡើយ។ តើគាត់ត្រូវធ្វើយ៉ាងដូចម្តេច?

១.តើលោកប៉ាង មានអារម្មណ៍យ៉ាងណា?

២.តើលោកប៉ាងអាចពន្យល់ បញ្ហារបស់គាត់ជាភាសារងស្តេសតាមរបៀបណា?

៣.តើគាត់អាចសួរសំណួរ របៀបណាទៅបុត្ររបស់គាត់?

៤.តើសំណួរអំពីកិច្ចការយកមកធ្វើផ្ទះរបៀបណា ដែលគាត់អាចយកមកសួរគ្រូបាន?

៥.តើគាត់អាចពិភាក្សាជាមួយអ្នកណា នៅសាលារៀន?

៦.តើគាត់អាចធ្វើអ្វីនៅផ្ទះ ដើម្បីជួយបុត្ររបស់គាត់អោយសិក្សាបានល្អ នៅសាលារៀន?

កិច្ចការអំពី ការចូលរួមសកម្មភាព ពីសំណាក់មាតាបិតា ដែលមិនសូវស្ទាត់ជំនាញខាង ភាសាអង់គ្លេស

ឯកសារ ៣

ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
ផ្នែកការសិក្សាអប់រំ សហគម និង ជនពេញវ័យ
ផ្នែកសម្រាប់ជនដែលមិនសូវស្ទាត់ជំនាញខាងភាសាអង់គ្លេស

និទាឃរដូវ ឆ្នាំ ១៩៩១

សមាសភាពទី ៣

មាតាបិតា គឺជា គ្រូបង្វឹកទី

ការបង្ហាញនូវកតវេទិតា

សមាសភាពទាំងអស់នេះ គឺកើតឡើងពីសហការរួម រវាង អ្នកស្រី **Diane Pecoraro** ផ្នែក ការសិក្សាអប់រំសំរាប់សហគម និងជនពេញវ័យ និងលោក **Bounlieng Phommasouvanh** ផ្នែកការសិក្សាអប់រំ សំរាប់ជនដែលមិនសូវស្គាត់ជំនាញ ខាងភាសាអង់គ្លេស។

អ្នកគ្រូ **Judith Strohl** ដែលជាគ្រូបង្រៀន **ABE/ESL** ពីមុន ហើយបច្ចុប្បន្ននេះជាគ្រូបង្រៀននៅអនុវិទ្យាល័យ **Sanford** នៅមីនីអាប៉ូលីស បានជួយសរសេរ និង តាក់តែងសម្ភារៈសិក្សាទាំងនេះដែរ។

និទាឃរដូវ ឆ្នាំ ១៩៩១

ចំពោះ អ្នកប្រើឯកសារនេះ
មានចលនាទូទៅក្នុងប្រទេស ដើម្បីពង្រឹង និង បង្កើនការចូលរួមសកម្មភាពពីសំណាក់មាតាបិតា
ក្នុងការសិក្សាអប់រំបុត្ររបស់លោកអ្នក។ យើងមានជំនឿ និង ទ្រទ្រង់លើមតិនេះ ជាពិសេស
ចំពោះមាតាបិតាសិស្សមិនសូវស្ទាត់ជំនាញលើភាសាអង់គ្លេស និងគ្រួសារជនភៀសខ្លួន ដែលមករស់នៅ
ស្រុកអាមេរិក ក្នុងរយៈពេល ២០ឆ្នាំក្រោយនេះ។ គ្រួសារទាំងនេះ បានប្រទះនឹងការពិបាកជាច្រើន អំពីបុត្រ
របស់ខ្លួនដែលកំពុងក្លាយខ្លួនជាអាមេរិកាំង និងអំពីរបៀបសិក្សាអប់រំនៅប្រទេសអាមេរិក ដែលមាន
សណ្ឋានភាពខុសគ្នា ពីរបៀបនៅប្រទេសអ្នក។

យើងបានបង្កើតសម្ភារៈសិក្សាសំរាប់ កម្មវិធីសិក្សាសំរាប់ជនពេញវ័យ ដូចជា កម្មវិធីសិក្សា
ភាសាអង់គ្លេសជាភាសាទីពីរ កម្មវិធីសិក្សាតាមអង្គការនៅសហគម និងតាមក្រុមមាតាបិតា
ក្នុងគោលបំណងដើម្បីជួយ មាតាបិតា និង អ្នកថែរក្សាក្មេង ដែលមិនសូវចេះភាសាអង់គ្លេស
អោយក្លាយទៅជាអ្នកចូលរួមយ៉ាងសកម្ម ក្នុងការសិក្សា អប់រំក្មេង។
ពេលដែលយើងរៀបចំឯកសារនេះ យើងមានគោលបំណង ÷
១.ជួយកសាងបន្ថែម ពីលើអ្វីដែលអ្នកបានធ្លាប់មានការពិសោធន៍ពីប្រទេសអ្នកមក។
២.ជួយបំភ្លឺមាតាបិតា អោយដឹងថា ខ្លួនជាគ្រូទី១ (ទស្សនៈ នេះតែងតែរលាយបាត់បង់ នៅពេលដែល
អ្នកភៀសខ្លួនមកនៅប្រទេសមួយទៀត)។
៣.ផ្តល់ឱកាសអោយ មាតាបិតាបញ្ចេញយោបល់មតិ អំពីអ្វីដែលខុសគ្នា និងដូចគ្នា រវាង វប្បធម៌ថ្មី និង ចាស់
ហើយបង្កើតស្ពានផ្ទាប់វប្បធម៌ទាំងពីរនេះ។
៤.ដើម្បីជួយជំរុញទឹកចិត្តមាតាបិតា អោយចេះអោយ និង រក្សាតម្លៃ និងទំនៀមទំលាប់ ដែលជាផ្នែកដ៏សំខាន់
នៃវប្បធម៌របស់គាត់។

វាជាភារកិច្ចមួយសំខាន់ណាស់ដែល យើងជួយពន្យល់មាតាបិតាដែលទើបអញ្ជើញមកដល់ថ្មី អោយបានយល់
អំពី របៀបសិក្សាអប់រំនៅស្រុកអាមេរិក ហើយដើម្បីអោយគាត់បាន យល់ដឹង ភារកិច្ចរបស់ខ្លួន លើការសិក្សា
អប់រំក្មេង។

គ្រូ អ្នកបង្ហាត់ និងប្រធានសហគម អាចយកឯកសារនេះទៅប្រើ ជាមួយមាតាបិតា ដើម្បីជាមធ្យោបាយ
ជួយមាតាបិតាក្នុងការបង្កើត បច្ចេកទេស និង ទំនុកចិត្តលើខ្លួនឯង ក្នុងការចោះជំហានទី១
ចំពោះការរួបរួមគ្នា ជាឆ្លងមួយ ក្នុងការសិក្សាអប់រំក្មេង។

ដោយក្តីរាប់អាន

អ្នកស្រី Diane Pecoraro
ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
(៦១២) ២៨៦-៣៥០០

Bounlieng Phommasouvanh
ក្រសួងសិក្សាអប់រំ រដ្ឋមីនីសូតា
(៦១២) ២៨៦-១០៦៨

ឬទ្ធកថា

ជួយឪ្យគ្រួសោកអ្នកអោយបានជោគជ័យនៅសាលារៀន

មាតាបិតាដែលទើបតែអញ្ជើញមកដល់ស្រុអាមេរិកថ្មីៗ តែងតែមានការព្រួយបារម្ភ ចំពោះការសិក្សា
របស់បុត្រខ្លួន និងមិនសូវដឹងអំពីភារកិច្ចរបស់ខ្លួន អំពីការសិក្សារបស់បុត្រខ្លួន។ មេរៀនបន្ទាប់ទៅនេះ
នឹងបកស្រាយឆ្លើយតបទៅនឹង បញ្ហាទាំងនោះ។ យើងបានរៀបចំមតិទស្សនៈ ដែលបញ្ជាក់ថា គ្រួសារ
គឺជាកត្តាមួយដ៏មានឥទ្ធិពល ដែលទាក់ទងទៅនឹង កិរិយាមារយាទ វិន័យ ការទាក់ទាញចំណង់ចិត្ត និង
ការអោយតម្លៃខ្លួនឯងរបស់សិស្ស។ លក្ខណៈទាំងអស់នេះ គឺមានឥទ្ធិពលដ៏ ខ្លាំងក្លា ហើយដែលទាក់ទងនឹង
ការជោគជ័យរបស់សិស្ស ក្នុងការសិក្សា។ លើសពីនេះទៅទៀត សម្ភភាពរបស់មាតាបិតា ក្នុងការណែ
នាំសិស្សនេះ មិនពឹងពាក់ទៅលើ ការស្ទាត់ជំនាញលើភាសាអង់គ្លេសទេ។

សម្ភារៈទាំងនេះ គឺសំដៅទៅលើ ការជួយមាតាបិតាអោយស្គាល់ សមត្ថភាពរបស់ខ្លួន
ក្នុងការចិញ្ចឹមថែរក្សាក្មេង ហើដើម្បីសង្កត់បញ្ជាក់ថែមទៀតថា បច្ចេកទេសដែលគាត់មាន
មានសារសំខាន់ណាស់។ ប្រធានដែល យើងនឹងយកមកបង្ហាញ គឺជាជំហានមួយដ៏មហិមា
ក្នុងការចាប់ផ្តើមពិភាក្សា និងជួយគ្នាទៅវិញទៅមក រវាងមាតាបិតានៅក្នុងក្រុមជាមួយគ្នា។

មានសមាសភាពមិសណ្ឋាន ÷

១. ចំណងពី វប្បធម៌ថ្មី និងវប្បធម៌ចាស់
សិក្សារបៀបថ្មី ប៉ុន្តែ រក្សារបៀបចាស់

២. សាលារៀន គឺជាផ្នែកមួយនៃវប្បធម៌

៣. មាតាបិតាគឺជាគ្រូ

មេរៀននីមួយៗ មានអត្ថបទអានខ្លីៗ ដែលនឹងផ្តល់ ការបំភ្លឺទៅចំពោះសម្ភារៈ លំហាត់មួយឬពីរ
ដើម្បីធ្វើអនុវត្តនិសាកល្បង និងពិភាក្សា ហើយនិងអត្ថបទរឿងអំពីបញ្ហាខ្លះៗ ដើម្បីអោយ
សមាជិកក្នុងក្រុមរែកញែក ដោះស្រាយ និងបញ្ចេញប្រតិកម្ម។

សកម្មភាពទាំនោះ អាចធ្វើតាម ពីរនាក់ ក្រុមតូចៗ ឬតាមក្រុមធំៗ ទៅតាមការសមគួរ។

យើងសង្ឃឹមថា គ្រួសារអាចបង្កើតបច្ចេកទេស និងបង្កើនទំនុកចិត្ត ក្នុងការចិញ្ចឹមថែរក្សាបុត្ររបស់ខ្លួន
ក្នុងសង្គមវប្បធម៌ថ្មី ហើយធ្វើអោយគាត់ចង់ចូលរួមជាសកម្ម ក្នុងការសិក្សារបរំ របស់បុត្រខ្លួន ទាំងនៅសាលា
និងនៅផ្ទះ។

ទស្សនៈទូទៅ

តាមការស្រាវជ្រាវអំពីភារកិច្ចរបស់មាតាបិតា នៅសាលារៀនបានបង្ហាញថា÷

*មាតាបិតាគឺជាគ្រូទី១ ហើយដែលមានឥទ្ធិពលជាងគេ។

*សាលារៀនចង់ និងត្រូវការជំនួយពីសំណាក់មាតាបិតា។

*ការនិយាយភាសាអង់គ្លេសរត់មាត់ មិនមែនជាការត្រូវការចាំបាច់ក្នុងការបង្កើត បរិយាការល្អ សំរាប់ការសិក្សាទេ។

*ការសិក្សារបស់សិស្ស អាចបានលូតលាស់ល្អនៅពេលមាតាបិតា÷

១.ជួយតម្កើង តម្លៃខ្លួនរបស់សិស្ស នេះរាប់បញ្ចូលទាំង ការអោយតម្លៃវប្បធម៌របស់គេផង។

២.បង្ហាញថា មាតាបិតាអោយតម្លៃទៅលើការសិក្សា ដោយទៅធ្វើទស្សនកិច្ច នៅសាលា សាកសួរអំពីសាលារៀន និងតាំងបង្ហាញកិច្ចការដែលសិស្សបានធ្វើជាដើម។

៣.និយាយ អាន និង ពន្យល់អំពី បញ្ហា ឬ របស់ផ្សេងៗ ។

៤.ពិនិត្យត្រួតមើល នូវចំនួនពេលម៉ោង និង ប្រភេទនៃកម្មវិធីទូរទស្សន៍ដែលក្មេងមើល។

៥.ចែកតារាងកាលវិភាគ សំរាប់ពេលម៉ោង ធ្វើកិច្ចការសាលារៀន បរិភោគអាហារ និង ពេលចូលដំណេក។

៦.រៀបចំកន្លែងពិសេស សំរាប់សិក្សានៅផ្ទះ។

៧.កំរិតចំនួនម៉ោង ដែលសិស្សអាចធ្វើការងារក្រោយម៉ោងសាលារៀន។

សម្ភាសភាព ទី ៣ ÷ មាតាបិតា គឺជា គ្រូបង្រៀន

លោកអ្នកគឺជាគ្រូមួយរូបដ៏សំខាន់បំផុត សំរាប់បុត្រលោកអ្នក។
ក្នុងមួយអាទិត្យៗ ក្មេងចំណាយពេល ៣៥ម៉ោងនៅសាលារៀន ហើយចំណាយ
ពេលច្រើនជាង ៥០ ម៉ោងនៅផ្ទះ ក្មេងរៀនបច្ចេកទេសសំខាន់ៗពីអ្នក
នៅចង្ក្រានបាយ ទីធ្លារនៅក្រៅផ្ទះ ឬនៅតាមផ្សារ។ កន្លែងនិមួយៗ
គឺជាកន្លែងសិក្សា។
បើក្មេងជួយនៅចង្ក្រានបាយ ក្មេងមើលតាមរបៀបដាំស្លៃ។
បើក្មេងជួយជួសជុលកង់ ក្មេងនឹងរៀនអំពី របៀបប្រើគ្រឿង ខ្ចៅខ្ចង
អោយបានត្រឹមត្រូវ។
បើក្មេងជួយក្នុងគ្រួសារ ក្មេងនឹងរៀនអំពីរបៀបចេះទទួលខុសត្រូវ។

គ្រួសារ គឺជា គ្រូ

ក. ត្រិះរិះអ្វីដែលអ្នករៀនពីគ្រួសាររបស់អ្នក កាលពីអ្នកនៅក្មេង។ ចូរសរសេរខាងក្រោមនេះ ÷

ឧទាហរណ៍ ÷ ការដាំដំណាំ
ការនិយាយត្រង់

១.

២.

៣.

៤.

៥.

៦.

សំណួរសំរាប់ពិភាក្សាបន្ថែម ÷ តើមាតាបិតាអ្នក បានបង្រៀនអ្នក អំពីកិច្ចការខាងលើនេះ តាមរបៀបណា?

ខ. និកក្នុងមនោគតិ ថា អ្នកកំពុងនៅក្នុងស្រុកកំណើតអ្នក។ តើស្ថិនខ្លះ ដែលលោកអ្នកចង់បង្រៀនបុត្រលោកអ្នក?

ឧទាហរណ៍ ÷ ការរកត្រី

ការចេះគោរពគ្រួសារចាស់ទុំ

១.

២.

៣.

៤.

៥.

៦.

សំណួរសំរាប់ពិភាក្សាបន្ថែម ÷ តើលោកអ្នក ត្រូវបង្រៀនបុត្រអ្នក អំពីកិច្ចការខាងលើនេះ តាមរបៀបណា?

គ. ត្រិះរិះអំពីអ្វីៗ ដែលលោកអ្នកបានបង្រៀនបុត្រលោកអ្នករួចហើយ។ ចូរសរសេរខាងក្រោមនេះ ÷

ឧទាហរណ៍ ការនិយាយត្រង់ មិនភូតភរ
ការលេងល្បែងកំសាន្ត

១.

២.

៣.

៤.

៥.

៦.

សំណួរសំរាប់ពិភាក្សាបន្ថែម ÷ តើអ្នក បានបង្រៀនបុត្រអ្នក អំពីកិច្ចការខាងលើនេះ តាមរបៀបណា?

ឃ. ត្រិះរិះអំពីអ្វីៗ ដែលលោកអ្នកចង់បង្រៀន បុត្រលោកអ្នកនៅអានាគត។ ចូរសរសេរ ខាងក្រោមនេះ ÷

ឧទាហរណ៍ ÷ របៀបជិះកង់

ការសរសេរអក្សរជាតិសាសន៍កំណើតរបស់ខ្ញុំ

១.

២.

៣.

៤.

៥.

៦.

សំណួរសំរាប់ពិភាក្សាបន្ថែម ÷ តើលោកអ្នក នឹងបង្រៀនបុត្រលោកអ្នក អំពីកិច្ចការខាងលើនេះ តាមរបៀបណា?

ជួយសិស្សអោយបានជោគជ័យក្នុងការសិក្សា

លេខ្យបអនុទត្ត

សូមអានហើយឆ្លើយ ថា ត្រូវ ឬ ខុស។ ហើយពិភាក្សា អំពីចម្លើយរបស់អ្នក ជាមួយនិងសិស្សម្នាក់ ដទៃទៀត។

_____១. បើអ្នកមិនសូវចេះភាសាអង់គ្លេស អ្នកមិនអាចជួយសិស្សក្នុងការសិក្សាបានទេ។

_____២. នៅសាលារៀន គ្រូចង់ដឹង ចង់បានយោបល់ និង គំនិត ពីសិស្ស។

_____៣. សិស្សរៀនអ្វីៗ ដែលសិស្សត្រូវរៀន នៅសាលារៀនតែមួយកន្លែងគត់។

_____៤. អ្នកអាចបង្រៀនអ្វីៗ ដែលសំខាន់ក្នុងរយពេល ១០-១៥ នាទី។

_____៥. សិស្សមិនត្រូវនិយាយពីរឿងប្បធម៌របស់ខ្លួននៅសាលារៀនទេ។

_____៦. និទានរឿងប្រាប់បុត្ររបស់អ្នកតាមភាសាកំណើត របស់អ្នកអាចជំនួយដល់ក្មេងក្នុងការសិក្សាភាសាអង់គ្លេស។

_____៧. មើលទូរទស្សន៍ ឬ ទូរទស្សន៍ភាពយន្ត ច្រើន អាចជួយសិស្សក្នុងការសិក្សាភាសាអង់គ្លេស។

_____៨. ក្មេងនឹងបានជោគជ័យក្នុងការសិក្សានៅសាលារៀន បើសិនសិស្សនោះបំភ្លេចភាសា និងវប្បធម៌កំណើតខ្លួន។

_____៩. បើសិនជាសិស្សនៅយប់ជ្រៅក្រ ចូលគេង(នៅក្នុងអាទិត្យដែល សិស្សត្រូវរៀន) អ្នកត្រូវនិយាយ " ល្អ"។

_____១០. បើសិនជាអ្នកលេងល្បែងកំសាន្តជាមួយសិស្ស ទៅស្លូចត្រី និង ធ្វើសួនច្បារ សិស្សនឹងសិក្សាបានល្អ។

_____១១. ជាទម្លាប់ល្អ ដែលសិស្សត្រូវធ្វើកិច្ចការសាលាដែលយកមកធ្វើនៅផ្ទះ ទៀងពេលរាល់ថ្ងៃ។

_____១២. គឺជាការមួយដ៏ល្អ ដែលសិស្សមធ្យមសិក្សា ត្រូវធ្វើការរកប្រាក់កំរៃ ក្រោយពេលចេញពីសាលារៀនរាល់ថ្ងៃ។

_____១៣. គឺជាការមួយដ៏ល្អ ដែលអ្នកមានសារពិតមាន ឬ សៀវភៅដែលសរសេរជាភាសាកំណើតអ្នក នៅផ្ទះ។

_____១៤. បើលោកអ្នកនាំសិស្ស ទៅលេង សួនសត្វ បណ្ណាល័យ និង សារមន្ទីរ សិស្សនឹងរៀនពូកែ។

_____១៥. សិស្សត្រូវការបន្ទប់ផ្ទាល់ខ្លួនមួយដើម្បីសំរាប់ធ្វើកិច្ចការសាលាដែលត្រូវយកមកធ្វើនៅផ្ទះ។

ជួយសិស្សអោយបានជោគជ័យក្នុងការសិក្សា

ចម្លើយ	សេចក្តីពន្យល់
១. ខុស	ទោះជាអ្នកមិនចេះភាសាអង់គ្លេសក៏ដោយ អ្នកក៏អាចជួយសិស្សក្នុងការសិក្សាបាន តាមមធ្យោបាយច្រើនយ៉ាង។ និទានរឿងតាមភាសាអ្នក គឺជាការមួយដ៏សំខាន់។ និយាយអំពីពិតមាន ជាមួយសិស្ស ទៅដើរលេងជាមួយសិស្ស នៅ សួនសត្វ និង បណ្ណាល័យជាដើម។ ទាំងអស់នោះ គឺជាសកម្មភាពសិក្សាដ៏សំខាន់។
២. ត្រូវ	សិស្សត្រូវតែសិក្សាពី ការពិត។ សិស្សត្រូវតែចេះបញ្ចេញយោបល់ ហើយពន្យល់ហេតុផល។
៣. ខុស	មាតាបិតា គឺជាគ្រូទី១ របស់សិស្ស។ សិស្សទៅរៀនត្រឹមតែ ៣០-៣៥ ម៉ោង ក្នុងមួយអាទិត្យ។ ក្រៅពីនោះសិស្សសិក្សារៀនសូត្រ ពីគ្រួសាររបស់ខ្លួន។
៤. ត្រូវ	ក្នុងរយពេល ៥-១០ នាទីបុត្ររបស់អ្នកអាចអនុវត្តកិច្ចការសំខាន់ៗ បានច្រើន។ ក្មេងតូច អាចទន្ទេញ ឈ្មោះ អាស័យដ្ឋាន ថ្ងៃខែកំណើត និង លេខទូរស័ព្ទ។ សិស្សអាចរៀនចំណេះ ស្រួលៗ ដូចជា រាប់លេខ ១ ២ ៣ ៤ ជាដើម។ សិស្សអាចរៀនប្រកបអក្សរ សំរាប់សាលារៀន។ ពេលតិចតួចនេះ អាចទៅជាពេលច្រើននៅពេលដែលយើងបូកបញ្ចូលគ្នាទៅ។
៥. ខុស	គ្រូចង់អោយសិស្សដឹងយល់អំពីវប្បធម៌របស់ខ្លួន។ គាត់ចង់អោយសិស្សដទៃទៀត យល់ដឹងពីវប្បធម៌របស់សិស្សរួមថ្នាក់ដែរ។
៦. ត្រូវ	បើអ្នកចេះដឹងរឿង តាមភាសាមួយ ការសិក្សាភាសាទីពីរ គឺ មានសភាពស្រួល។ សិស្សនឹងដឹងជាស្រេច នូវបញ្ហា និងរបៀបដោះស្រាយបញ្ហា និងរបៀបដែលពីរបុរស/នារី អនុវត្ត។ សិស្ស នឹង យល់ថា គំនិត និង យោបល់ មានសភាពដូចគ្នាតនៅក្នុងភាសាអង់គ្លេសដែរ។
៧. ខុស	ការមើលទូរទស្សន៍បន្តិចបន្តួច មិនជាអ្វីទេ ប៉ុន្តែការចំណាយពេលច្រើនជាងពីរម៉ោង ក្នុងមួយថ្ងៃ គឺជាការមួយមិនល្អទេ។ មាតាបិតាគួរតែ ជ្រើសរើស កម្មវិធីល្អៗ សំរាប់ក្មេងមើល។ ពេលខ្លះ អ្នកអាចមើលកម្មវិធីទូរទស្សន៍ជាមួយសិស្ស។ បន្ទាប់មកអ្នកអាចពិភាក្សា អំពី អ្វីខ្លះ ល្អ អ្វីខ្លះអាក្រក់ ដែលអ្នកទើបតែទស្សនា។
៨. ខុស	សិស្សរៀនពូកែ នៅពេលដែលសិស្សមានអារម្មណ៍ល្អអំពីខ្លួន គ្រួសារ និង វប្បធម៌។ សិស្សនឹងមិនមានការខ្មាស់អៀន ឬ ខ្លាចក្នុងការបញ្ចេញយោបល់នឹងក្នុងការសាកល្បងកិច្ចការថ្មីៗ។

៩. ខុស សិស្សនឹងរៀនពូកែ នៅពេលដែលសិស្សបានគេងគ្រប់គ្រាន់។ សិស្សគួរតែចូលគេងទៀងពេលរៀងរាល់ថ្ងៃ ពីព្រោះនេះជាការមួយដ៏ល្អ។

១០. ត្រូវ គឺជាការមួយដ៏ល្អ ដែលអ្នកគួរតែលេងល្បែងកំសាន្តជាមួយសិស្ស។ សិស្ស នឹងរៀនអនុវត្តតាមក្បួនវិន័យ។ល្បែងដូចជា អុក ឬ ហៀរ(សំរាប់កំសាន្ត)អាចបង្រៀនអោយសិស្សចេះគិតជាមុនដើម្បីឈ្នះ។

១១. ត្រូវ មាតាបិតាខ្លះ ចូលចិត្តអោយសិស្សធ្វើកិច្ចការសាលា មុនមើលទូរទស្សន៍ ឬ លេងល្បែងផ្សេងៗ។

១២. ត្រូវ តែ សិស្ស មិនចាំបាច់ធ្វើការច្រើនម៉ោងទេ។ បើសិស្សធ្វើការច្រើនពេក នាំអោយសិស្សមានការពិបាកក្នុងការធ្វើកិច្ចការសាលារៀន ហើយនឹងមិនបានគេងគ្រប់គ្រាន់។

១៣. ត្រូវ បើសិស្សឃើញគ្រួសារវារអាន សិស្សនឹងចង់អានតាមដែរ។ សិស្សនឹងបានយល់ឃើញថា ក្នុងសៀវភៅមានគំនិតល្អៗ ច្រើន ហើយការអាននាំមកនូវការរីករាយផង។

១៤. ត្រូវ បើសិស្សបានដើរទៅកន្លែងផ្សេងៗ នៅទីក្រុង និង ឋ្ឋ សិស្សនឹងបានឃើញអ្វីៗច្រើន ហើយសិស្សក៏នឹងបានសិក្សារបស់ទាំងនោះនៅសាលារៀនដែរ។ សិស្សនឹងអានដឹងជាមុនស្រេចនូវរបស់ទាំងនោះដូច្នេះសិស្សនឹងពុំសូវមានការពិបាក ក្នុងការសិក្សារបស់ទាំងនោះនៅសាលារៀនឡើយ។

១៥. ខុស សិស្សមិនចាំបាច់មានបន្ទប់ផ្ទាល់ខ្លួនទេ តែសិស្សត្រូវការកន្លែងពិសេស សំរាប់រៀបចំទុកដាក់កិច្ចការសាលារបស់វា។ សិស្សត្រូវការកន្លែងដែលវាអាចធ្វើកិច្ចការសាលារៀន ដែលត្រូវយកមកធ្វើនៅផ្ទះរាល់ថ្ងៃ។

តើមាតាបិតាអាចជួយសិស្សតាមវិធីណា?

លេខ្យៃបអនុទត្ត

សូមអានបញ្ជីរខាងក្រោម ហើយសរសេរសញ្ញា " X " នូវឃ្លាដែលបញ្ជាក់នូវអ្វីៗ ដែលអ្នកបានអនុវត្ត ក្នុងពេលបច្ចុប្បន្ននេះ ហើយសរសេរសញ្ញា " • " នូវឃ្លាដែលបញ្ជាក់នូវអ្វីៗ ដែលអ្នកចង់អនុវត្តក្នុងពេលអនាគត។ ជ្រើសរើសកិច្ចការអ្វីមួយដែលអ្នកនឹងសាកល្បងធ្វើអាទិត្យក្រោយ ហើយគូសរង្វង់លើឃ្លានោះ។ ប្រាប់ក្រុមរបស់អ្នក នូវគម្រោងការរបស់អ្នក។

អោយសិស្សទៅសាលាដើម្បីត្រៀមខ្លួនចាំសិក្សា

--ត្រូវអោយសិស្សគេងអោយឆ្អែត។

--ត្រូវអោយសិស្សបរិភោគអាហារព្រឹកបានត្រឹមត្រូវ។

--ត្រូវមានកន្លែងស្ងាត់ សំរាប់សិស្សសិក្សា និង រក្សាកិច្ចការសាលារៀនរបស់វា។

--ត្រូវរៀបចំកន្លែងនៅក្នុងផ្ទះសំរាប់សិស្សដាក់ទុកប្រដាប់ប្រដារដែលត្រូវយកទៅរៀននៅពេលព្រលឹម។

--កុំអោយសិស្សមើលទូរទស្សន៍ច្រើនពេក។

--ជួយរៀបចំសិស្សក្នុងការជ្រើសរើសសំលៀកបំពាក់(នៅពេលយប់ មុនចូលគេង)សំរាប់ពាក់ទៅរៀនពេលព្រលឹម។

ជួយតាំក្នុសាលារៀន ហើយ បច្ចាញអោយយើញថា អ្នកគិតថាសាលារៀន មានសារៈសំខាន់ណាស់

--ដាក់ព្យួរតាំង កិច្ចការសិស្សដែលបានយកមកពីសាលារៀន។

--និយាយពិភាក្សាអំពីសាលារៀន។ សាកសួរសិស្សអំពីកិច្ចការដែលសិស្សបានធ្វើ ឬ កើតឡើងនៅសាលារៀន។

--ទៅបណ្ណាល័យសាលារៀនទៀងទាត់ជាមួយសិស្ស។

--ទៅសាលារៀនចូលរួមក្នុងកម្មវិធីផ្សេងៗ ឬ ប្រជុំជាមួយគ្រូ។

--រោយសិស្សអានរោយអ្នកស្តាប់ ទោះបីជាអ្នកស្តាប់មិនយល់ក៏ដោយ។

--ពិនិត្យមើលបំណែរបាយការសិក្សារបស់សិស្ស។ ទូរស័ព្ទទៅសាលារៀនបើសិនជាអ្នកមើលមិនយល់។ តាមធម្មតា សាលារៀន តែងតែមានអ្នកបកប្រែភាសា។

--ពិនិត្យមើលថាតើសិស្សបានធ្វើកិច្ចការសាលារៀនចប់ឬនៅ។ សិស្សអាចទុកបញ្ជីរកិច្ចការសាលារៀន ក្នុងកូនសៀវភៅមួយ សំរាប់អ្នកពិនិត្យមើល។

អនុទត្តលំហាត់ការសិក្សានៅផ្ទះ

--ចំណាយពេលជាមួយសិស្ស។ ក្មេងខ្លះ ចូលចិត្តនិយាយនៅពេលជិះឡាន ខ្លះទៀតចូលចិត្តនិយាយ នៅពេលធ្វើកិច្ចការផ្ទះ។

--និយាយអំពីរឿ្ង ដែលក្មេងអាច ស្តាប់ឮ ឃើញ ស្តាប ភ្លក់ និង ហិត បាន។

--ពេលមើលទូរទស្សន៍ សាកសួរក្មេងនូវសំណួរ អំពី អ្នកណា កន្លែងណា ពេលណា និង ហេតុអ្វី ជាដើម។

<u>លំហាត់សំរាប់សាកល្បងធ្វើនៅផ្ទះ</u>

ខាងក្រោមនេះ គឺជាគំនិតខ្លះសំរាប់អ្នក បើអ្នកចង់សាកល្បងធ្វើលំហាត់ខ្លះៗនៅផ្ទះ ដើម្បីជួយសិស្សក្នុងការសិក្សា

ការហាត់អាន

អានសៀវភៅ ហើយ ត្រូវអានឯកសារដទៃទៀតដែរ។ ដូចជា សញ្ញាផ្សេងនៅតាមផ្លូវ ផ្ទាកនៅលើកញ្ចប់អាហារ ប្រក្រតីទិន មុខម្ហូបអារហារនៅសាលារៀន ឈ្មោះអ្នកក្នុងសៀវភៅបញ្ជីរទូរស័ព្ទ និង សំបុត្រមកពី ស្រុកកំណើតអ្នក ជាដើម។

ទូរស័ព្ទ

ទូរស័ព្ទទៅហាងទំនិញ ដើម្បីសួរតម្លៃរបស់ផ្សេងៗ។

ទូរស័ព្ទ ទៅសាកសួរពិតមានអំពីរថយន្តក្រុងជាដើម។

ទូរស័ព្ទ ទៅកន្លែងជំនួយ ក្នុងការធ្វើកិច្ចការសាលារៀន បើសិនជាមានកន្លែងគេជួយ។

កន្លែងត្រូវទៅ

ទៅទស្សនាកន្លែងផ្សេងៗ ដែលនៅជិតខាងរបស់អ្នក។ ទៅកន្លែង ក្រុមអគ្គីភ័យ ចំណតយន្តហោះ កន្លែងដាំដំណាំ មជ្ឈមណ្ឌលធម្មជាតិ ស្ថានីយ៍ទូរទស្សន៍ ចំការ ឬ ហាងលក់សត្វជាដើម។

ការហាត់សរសេរ

សរសេរពាក្យផ្គាំផ្ញើតាមទូរស័ព្ទ។ សរសេរបញ្ជីរបស់របរដែលត្រូវទៅទិញ និងកិច្ចការដែលត្រូវធ្វើ។ សរសេរសំបុត្រទៅ មិត្តភ័ក្ត្រ ឬ សមាជិកនៅក្នុងគ្រួសារ។ លាក់សំបុត្រ នៅក្នុងហោប៉ៅអ្នកដទៃ ដោយមិនអោយដឹងមុន។

ការហាត់និយាយ

ចាប់ផ្តើមនិទានរឿង ហើយឈប់នៅកន្លែងដែលមានចម្ងល់ ហើយអោយក្មេង គិតអំពីសាច់រឿងបញ្ចប់ ហើយអោយវាបញ្ចប់សាច់រឿងនោះ។ ច្រៀង សូត្រកំណាព្យ និទានរឿងហើយ ថតចូលក្នុងម៉ាស៊ីនថតសម្លេង ហើយ ស្តាប់ ជាមួយក្មេង។